# សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ
# UNIVERSITY OF SOUTH-EAST ASIA

ជំនាញ

ឧត្តមភាព

សង្គម

Skills. Excellence. Social

USEA

# ប្រធានបទស្តីពី

## ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្ត សៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុង គ្រួសារ

សាស្ត្រាចារ្យដឹកនាំ ៖ ច័ន្ទ ចំរើន

ស្រាវជ្រាវដោយ ៖

និស្សិត ប៊ុន ឈុនណាយ

និស្សិត គាន ស៊ីឡាក់

និស្សិត ស៊ា ចាន់នី

និស្សិត ស៊ុយ ច័ន្ទថី

និស្សិត ផាន ស៊ាងអំ

# មាតិកា

១. សេចក្តីផ្តើម
២. រំលឹកទ្រឹស្តី
៣. វិធីសាស្ត្រស្រាវជ្រាវ
៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា
៥. សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ១. សេចក្តីផ្តើម

## ១.១- លំនាំបញ្ហា

មនុស្សគ្រប់រូប គឺពិតជាត្រូវការសិទ្ធិ និងសេរីភាពរបស់ខ្លួនខ្លាំងណាស់នៅក្នុងការធ្វើកិច្ចការងារ ឬការដើរហើរជាដើម ។ ក៏ដូចគ្នានេះដែរ ដោយមើលឃើញថាស្ត្រីគឺជាភេទមួយដែលងាយនឹងទទួលរងគ្រោះពីការរំលោភបំពានផ្សេងៗ ដែលមានដូចជា ការរំលោភបំពានទៅលើផ្លូវភេទ និងការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារជាដើម ។ ដោយហេតុនេះហើយទើបរដ្ឋាភិបាល ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗបានខិតខំយកចិត្តទុកដាក់ទៅលើបញ្ហានេះ ដូចជាការអនុវត្តទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងតាមដាននូវការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ចជាដើម ។ ដោយហេតុនេះហើយ ទើបក្រុមយើងខ្ញុំសម្រេចជ្រើសយកប្រធានបទ ៖ ដើម្បីធ្វើការស្រាវជ្រាវបញ្ចប់នូវថ្នាក់បរិញ្ញាបត្រ នៃមហាវិទ្យាល័យវិទ្យាសាស្រ្តសង្គម "ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ" និងនីតិសាស្រ្ត ឯកទេសនីតិឯកជន ។

# ១. សេចក្តីផ្តើម (ត)

## ១.២- ចំណោទបញ្ហា និងសំណួរស្រាវជ្រាវ

ដោយហេតុថា បញ្ហានៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ជាបទល្មើសមួយដែលតែងតែកើតមានឡើងជារឿយៗផងដែរនៅក្នុងសង្គមកម្ពុជា ហើយយើងគួរតែយកចិត្តទុកដាក់ក្នុងការលុបបំបាត់ចោលឲ្យអស់ពីសង្គម ដូចនេះហើយ ទើបបានជាយើងចង់ដឹង និងបញ្ជាក់ថា សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប នឹងមាននូវចំណាត់ការ និងយន្តការយ៉ាងដូចម្តេចខ្លះចំពោះបញ្ហាទាំងនេះ ។ ចំពោះជាសំណួរចោទដើម្បីស្រាវជ្រាវនោះគឺ ៖ តើសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ប្រចាំខេត្តសៀមរាប មានវិធានការយ៉ាងដូចម្តេចខ្លះ ដើម្បីធ្វើការការពារទៅលើសិទ្ធិស្ត្រីនៅពេលដែលមានការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ?

# ១. សេចក្តីផ្តើម (ត)

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

- ស្វែងយល់អំពីមូលហេតុនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រីនៅក្នុងខេត្តសៀមរាបនាពេលបច្ចុប្បន្ន
- ស្វែងយល់អំពីយន្តការនៃការការពារសិទ្ធិស្ត្រីអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ
- សិក្សាប្រៀបធៀបទ្រឹស្តីនៃការការពារសិទ្ធិស្ត្រីអំពីការរំលោភបំសេពសន្ថវៈ ពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារទៅនឹងការអនុវត្តជាក់ស្តែង ។

# ២. រំលឹកទ្រឹស្តី

## ២.១- និយមន័យ

### ក. ការរំលោភសេពសន្ថវៈ

ការរំលោភសេពសន្ថវៈ សំដៅទៅលើអំពើផ្លូវភេទ ឬអារម្មណ៍ផ្លូវភេទ ដែលបានបញ្ចូលអង្គជាតតាមបែបណាក៏ដោយ ឬអំពើដែលបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលបានប្រព្រឹត្តទៅលើអ្នកដទៃ ដែលធ្វើឲ្យមនុស្សម្នាក់នោះយល់ថាខ្លួនមិនមានអារម្មណ៍ថាសុខស្រួល ដោយទទួលរងការគំរាមកំហែង ឬភ័យខ្លាច ការប្រើហិង្សា និងការបង្ខិតបង្ខំជាដើម ។



# ២. រំលោភទ្រឹស្តី ( ត )

## ខ. អំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

អំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ជាអំពើណាមួយនៃអំពើហិង្សាដែលបង្កឲ្យមានការឈឺចាប់ ឬធ្វើទុកបុកម្នេញទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទដល់ស្ត្រី ដោយរួមមាន ការគំរាមគំហែង ការធ្វើទារុណកម្ម ឬអំពើឃោរឃៅណាមួយនៃការប្រព្រឹត្តអំពើនោះ ។



# ២. រំលឹកទ្រឹស្តី ( ត )

## ២.១.១- ប្រភពដែលបង្កើតឱ្យមានការការពារទៅលើសិទ្ធិស្ត្រី

### ក. ច្បាប់អន្តរជាតិ

ចំពោះច្បាប់អន្តរជាតិ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលបានតាក់តែងក្នុងគោលបំណងដើម្បីលើកកម្ពស់  និងការពារសិទ្ធិដល់ស្ត្រីនោះរួមមានដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា ២ និងមាត្រា ២១) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (មាត្រា ១, ៣, ៤, ៥ និងមាត្រា ៦) សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (មាត្រា ១៧)  កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រ ២, ៣ និងមាត្រា ២៥) កិច្ចព្រមព្រៀងទីក្រុងប៉ារីស (មាត្រា ១៥ និងមាត្រា ១៧) ។

# ២. រំលឹកទ្រឹស្តី (ត)

## ខ. ច្បាប់ជាតិ

ចំណែកឯច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ជាតិវិញ ក៏បានរួមបញ្ចូលនូវចំណុចមួយចំនួនទាក់ទងទៅនឹងសិទ្ធិស្ត្រីផងដែរដែលមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ (មាត្រា ៣១, ៣២, ៣៦, ៣៨, ៤៥ និងមាត្រា ៤៦) ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ (មាត្រា ២១៧ រហូតដល់មាត្រា ២៣០ និងមាត្រា ២៣៩ រហូតដល់មាត្រា ២៥៥) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (មាត្រា ១ រហូតដល់មាត្រា ៧) ច្បាប់ស្តីពីការងារ (មាត្រា ១ និងមាត្រា ១៨២ រហូតដល់ មាត្រា ១៨៦) ។

# ២. រំលឹកទ្រឹស្តី (ត)

## ២.១.២- ទោសបញ្ញត្តិអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

រាល់ការកើតមានឡើងនូវអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារដែលត្រូវបានរាប់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយផ្អែកទៅលើច្បាប់ព្រហ្មទណ្ឌជាធរមាន ហើយទោសបញ្ញត្តិនីមួយៗត្រូវបានកំណត់ទៅតាមទំហំនៃបទល្មើសនោះ ដែលមានចែងនៅចាប់ពីមាត្រា ២៣៩ រហូតដល់មាត្រា ២៥២ និងមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ។

## ២.២- បទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ

នៅក្នុងចំណុចនៃបទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងនឹងប្រធានបទនេះ ត្រូវបានរួមបញ្ចូលទ្រឹស្តីសំខាន់ៗទាក់ទងទៅនឹង មូលហេតុនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី និងយន្តការទប់ស្កាត់ ។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

## ៣.១- ទីកន្លែង ឬអង្គភាព

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប មានទីតាំងស្ថិតនៅភូមិ សាលាកន្សែង សង្កាត់ ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប មានវិសាលភាពគ្របដណ្តប់ទូទាំងខេត្តសៀមរាប ហើយនៅជុំវិញសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប គឺមានផ្ទះប្រជាពលរដ្ឋជាច្រើន ។

# ៣. វិធីសាស្ត្រស្រាវជ្រាវ ( ត )

## រូបភាព ទីកន្លែង ឬអង្គភាពស្រាវជ្រាវ



# ៣. វិធីសាស្ត្រស្រាវជ្រាវ ( ត )

## ៣.២- ប្រភេទនៃការស្រាវជ្រាវ

ប្រភេទនៃការស្រាវជ្រាវលើប្រធានបទ ក្រុមរបស់យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្របែបពិពណ៌នា ដោយផ្អែកលើទិន្នន័យពីរគឺ ទិន្នន័យចម្បង ឬទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យដែលមានស្រាប់ ។

## ៣.៣- ការជ្រើសរើសសំណាក

ការជ្រើសរើសសំណាក ក្រុមរបស់យើងខ្ញុំបានធ្វើការសម្ភាសន៍ដោយផ្ទាល់មាត់ ជាមួយនឹងប្រធានផ្នែកស្ត្រី និងប្រធាននៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប និងបុគ្គលិកទទួលបន្ទុកផ្នែកផ្សេងៗទៀតនៅក្នុងសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាបនោះ ដើម្បីទទួលបានទិន្នន័យក្នុងការសាកសួរ ។

# ៣. វិធីសាស្ត្រស្រាវជ្រាវ ( ត )

## ៣.៤- វិធីសាស្ត្រវិភាគទិន្នន័យ

ក្រុមរបស់យើងខ្ញុំបានយកទិន្នន័យដែលប្រមូលបាននោះ មកធ្វើការវិភាគដោយជ្រើសរើសយកវិធីសាស្ត្រវិភាគទិន្នន័យ តាមបែបគុណវិស័យមកធ្វើការវិភាគ ដែលជាការវិភាគដោយប្រើប្រាស់ទិន្នន័យ ឬព័ត៌មានទាំងឡាយដែលបានមកពីការសម្ភាសន៍ដោយផ្ទាល់មាត់ ។

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

## ៤.១- លទ្ធផលស្រាវជ្រាវ

សមាគមអាដហុក បានធ្វើការទៅលើរឿងពីរផ្នែកធំៗ គឺផ្នែកគាំពារសិទ្ធិមនុស្ស និងដីធ្លី ហើយនិងសិទ្ធិស្ត្រី និងកុមារ ដែលមានសកម្មភាពសំខាន់ៗ ៣ គឺ ៖

- សកម្មភាពឃ្លាំមើល និងអន្តរាគមន៍ ៖ ជាការសិក្សាស្វែងរកការពិតទៅតាមករណីនីមួយៗ ការផ្តល់ដំបូន្មានផ្នែកច្បាប់ និងការផ្តល់សម្ភារ ជំនួយផ្នែកសុខភាព និងការធ្វើមាតុភូមិនិវត្តន៍ដល់ជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្ម និងពលករចំណាកស្រុក ។
- សកម្មភាពពង្រឹងសិទ្ធិអំណាច ៖ ជាការផ្តល់វគ្គបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាព ការរៀបចំសិក្ខាសាលា កិច្ចប្រជុំ ឬការកសាងបណ្តាញ ។
- ការតស៊ូមតិ ៖ ជាការធ្វើសន្និសិទការសែត ធ្វើសេចក្តីថ្លែងការណ៍ របាយការណ៍តាមវិស័យផ្សេងៗ កិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ និងជនរងគ្រោះ ដើម្បីលើកទឹកចិត្តឱ្យពួកគេចែករំលែកនូវព័ត៌មាន និងស្វែងរកដំណោះស្រាយរួម

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ៤.២- ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

នៅក្នុងផ្នែកនៃលទ្ធផលស្រាវជ្រាវនេះ ក្រុមយើងខ្ញុំនឹងធ្វើការលើកឡើងអំពីចំណុចសំខាន់ៗដែលមានដូចជា ៖ កត្តាដែលបណ្តាលឱ្យកើតមានឡើងនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ នីតិវិធី ឬដំណើរការនៃការអនុវត្តការការពារសិទ្ធិស្ត្រីដោយផ្តោតសំខាន់ទៅលើការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាប្រឈមរបស់អង្គភាពក្នុងការអនុវត្តនូវសកម្មភាពនានា ។

ដោយយោងទៅតាមការធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយនិងមន្រ្តីគម្រោងការពារសិទ្ធិស្ត្រី និងកុមារ ក្រុមយើងខ្ញុំបានទទួលនូវសំណុំរឿងចំនួន ២០ ករណី ដែលក្នុងនោះមាន ៨ សំណុំរឿងទាក់ទងនឹងករណីរំលោភបំពានផ្លូវភេទ និង ១២ ករណី ទាក់ទងទៅនឹងករណីអំពើហិង្សាក្នុងគ្រួសារ ។ នៅក្នុងនោះដែរក្រុមយើងខ្ញុំបានពិនិត្យមើលឃើញថា សំណុំរឿងទាំង ២០ ករណី គឺជាបទល្មើសព្រហ្មទណ្ឌ ដោយនៅក្នុងករណីទាំង ២០ នោះ គឺមានបណ្តឹងរដ្ឋប្បវេណីចំនួន ២ ដែលជនរងគ្រោះស្នើសុំលែងលះប្តីរបស់ ខ្លួន។

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ៤.២.១- ប្រភេទនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ

### ក. ការរំលោភបំពានផ្លូវភេទ



# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ខ. ករណីអំពើហិង្សាក្នុងគ្រួសារ



# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ៤.២.២- មូលហេតុដែលបង្កើតឱ្យមានការរំលោភបំពាន

### ក. ករណីរំលោភសេពសន្ថវៈ

- ជនបង្កជាមនុស្សញៀនស្រា
- ជនបង្កជាមនុស្សដែលមានចំណង់ផ្លូវភេទខ្លាំង ឬល្មោភកាម
- ឪពុកចុងគ្មានមនោសញ្ចេតនាជាមួយនឹងកូនដើម
- ម្ដាយទៅធ្វើការនៅឆ្ងាយទុកកូនស្រីឱ្យនៅជាមួយគេ
- ជនរងគ្រោះជាមនុស្សមានសតិមិនគ្រប់
- ជនរងគ្រោះភាគច្រើនជាក្មេងស្រីហើយរស់នៅម្នាក់ឯង ឬជាមួយបងប្អូនតូចៗ
- ស្ថានភាពផ្លូវមិនស្រួល ហើយស្ងាត់ជ្រងំដែលជាឱកាសដល់ជនបង្កធ្វើសកម្មភាព
- ភាគច្រើននៃជនបង្កជាមនុស្សដែលមានកម្រិតវប្បធម៌តិចតួចបំផុតដែលជាហេតុធ្វើឱ្យពួកគាត់មិនសូវមានការពិចារណានូវអំពើនេះ

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ខ. ករណីអំពើហិង្សាក្នុងគ្រួសារ

- ទំនាស់ពាក្យសម្ដីរវាងបង និងប្អូនពីរឿងធ្វើបង្គន់ចូលក្នុងដីគ្នា
- ប្ដីជាមនុស្សញៀនស្រាជារៀងរាល់ថ្ងៃ
- ទំនាស់ពាក្យសម្ដីគ្នារវាងប្ដីប្រពន្ធបន្តិចម្ដងៗរហូតក្លាយទៅជាជម្លោះធំ
- មួយចំនួនធំផងដែរកើតឡើងពីការប្រចណ្ឌរវាងប្ដី និងប្រពន្ធ
- ប្រពន្ធសុំលែងលះច្រើនដងតែប្ដីមិនព្រមរហូតដល់មានអំពើហិង្សា
- ប្ដី ឬប្រពន្ធលួចមានអ្នកថ្មី (សាហាយស្មន់ មានទាំងប្ដីទាំងប្រពន្ធ)
- ចាប់បង្ខំប្រពន្ធឱ្យរួមភេទជាមួយនឹងអ្នកដទៃ
- គ្រួសារមានជីវភាពក្រីក្រ និងមានកម្រិតវប្បធម៌ទាប

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ៤.៣- គុណសម្បត្តិ និងគុណវិបត្តិនៃការគាំពារសិទ្ធិ

តាមរយៈការជួយការពារសិទ្ធិជូនប្រជាពលរដ្ឋរបស់អាដហុក ក៏មាននូវគុណសម្បត្តិ និងគុណវិបត្តមួយចំនួនដូចជា ៖

### ក. គុណសម្បត្តិ

- ជួយឱ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិរបស់ខ្លួនពីការរំលោភបំពានផ្សេងៗដែលកើតមានឡើងចំពោះខ្លួន
- ជួយពន្លឿននូវនីតិវិធីនៃដំណើរការសំណុំរឿងចាប់ពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលនីតិវិធីតុលាការ
- ជាជំនួយនៅក្នុងការដាស់តឿនអាជ្ញាធរមានសមត្ថកិច្ច ឱ្យដោះស្រាយបញ្ហាជូនប្រជាជនដោយមិនទុករឿងចោលឥតចាត់ការ
- ធ្វើឱ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រីរងគ្រោះ ឱ្យទទួលបានយុត្តិធម៌ក្នុងករណីមានអំពើរំលោភបំពានផ្សេងៗ

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា ( ត )

## ក. គុណសម្បត្តិ ( ត )

- មិនបណ្ដោយឱ្យជនដែលប្រព្រឹត្តអំពើអាក្រក់រួចខ្លួន
- ប្រឹក្សាអំពីបញ្ហានានាដល់ពលរដ្ឋ ជាពិសេសស្ត្រីដែលបានជួបនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃឱ្យទទួលបាននូវវិធាន និងមាគ៌ាក្នុងការដើរទៅមុខទៀត
- ការរក្សាការសម្ងាត់ជូនជនរងគ្រោះដែលមានការរំលោភបំពាន ដែលនេះជាការដែលអាចរក្សាតម្លៃថ្លៃថ្នូរក្នុងភាពជាមនុស្សជាតិ
- ផ្សព្វផ្សាយឱ្យប្រជាពលឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួន វិធីការពារ និងការស្វែងរកអង្គការ ឬសមាគមដែលអាចជួយដោះស្រាយបញ្ហាទាំងនោះបាន
- ធ្វើឱ្យប្រជាពលរដ្ឋទទួលបាននូវការប្រឹក្សាផ្នែកច្បាប់មួយដ៏ត្រឹមត្រូវ
- ផ្ដល់ជាជំនួយមេធាវី ជំនួយហិរញ្ញវត្ថុទៅលើផ្នែកមួយចំនួនចំពោះជនរងគ្រោះដែលមានជីវភាពខ្វះខាត ។

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ខ. គុណវិបត្តិ

- អាជ្ញាធរមានសមត្ថកិច្ចមួយចំនួនមិនព្រមដោះស្រាយបញ្ហាជូនប្រជាជន ដោយទុកសំណុំរឿងឥតចាត់ការ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានផលលំបាក
- មន្ត្រីទទួលបន្ទុកផ្នែកសិទ្ធិនារីគឺជាស្ត្រីតែម្នាក់ឯង ដែលពេលខ្លះធ្វើឱ្យមានការព្រួយបារម្ភចំពោះសុវត្ថិភាពដូចគ្នា
- ជនល្មើសបានរត់គេចខ្លួនបាត់ ដោយធ្វើឱ្យមានការពិបាកនៅក្នុងការស្វែងរក ដែលជាពិសេសធ្វើឱ្យសំណុំរឿងកាន់តែអូសបន្លាយ
- គ្មានអ្នកទទួលខុសត្រូវចំពោះជនរងគ្រោះ ព្រោះជនប្រព្រឹត្តិបានសម្លាប់ខ្លួនឯងដូចគ្នា
- ជនរងគ្រោះមិនព្រមសហការជាមួយនឹងមន្ត្រីទទួលផ្ទុកផ្នែកសិទ្ធិស្ត្រី និងអាជ្ញាធរដើម្បីបំភ្លឺការពិត
- មន្ត្រីអនុវត្តសកម្មភាពមានគ្នាតិច ធ្វើឱ្យការធ្វើការមិនសូវលឿនខ្លាំង ។

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ៤.៣.១- បញ្ហាប្រឈមចំពោះការអនុវត្ត

### ក. បញ្ហាប្រឈមរបស់មន្ត្រីដែលចុះអនុវត្តផ្ទាល់

ដោយផ្អែកទៅលើការសម្ភាសន៍ផ្ទាល់ជាមួយនឹងប្រធានផ្នែកសិទ្ធិស្ត្រី និងកុមារ បានឱ្យដឹងថា ពួកគាត់មានបញ្ហាប្រឈមជាច្រើនដូចជា ៖

- ស្ថានភាពផ្លូវឆ្ងាយ ស្ងាត់ អសន្តិសុខ
- ប្រឈមជាមួយនឹងភាគីខាងប្រព្រឹត្ត
- ពេលខ្លះ ជនរងគ្រោះខ្វះការសហការ

### ខ. បញ្ហារបស់សមាគមផ្ទាល់

ដោយផ្អែកទៅលើការសម្ភាសន៍ផ្ទាល់ជាមួយនឹងមន្ត្រីគម្រោងការពារសិទ្ធិស្ត្រី និងកុមារ បានឱ្យដឹងថា ពួកគាត់មានបញ្ហាប្រឈមជាច្រើនដូចជា ៖

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា (ត)

## ខ. បញ្ហារបស់សមាគមផ្ទាល់ (ត)

- ករណីមួយចំនួននៅពេលមានករណីរំលោភបំពានកើតឡើង អាជ្ញាធរនៅក្នុងតំបន់មួយចំនួនហាក់ដូចជាមានការសហការជាមួយសមាគមនៅមានកម្រិត ដែលជាហេតុធ្វើឱ្យល្បឿននៃការដំណើរការនីតិវិធីរកយុត្តិធម៌ជូនជនរងគ្រោះ ក៏មានភាពយឺតយ៉ាវផងដែរ
- ករណីការរំលោភបំពានសេពសន្ថវៈ នៅពេលដែលគាត់ទទួលបានសំណងពីភាគីបង្កហើយ ជនរងគ្រោះបានដកពាក្យបណ្ដឹងវិញ ដូច្នេះហើយ ក្នុងករណីនេះសមាគមក៏ពិបាកនូវក្នុងការដំណើរក្ដីរកយុត្តិធម៌ផងដែរ ហើយក៏មានការលំបាកខ្លះៗក្នុងការស្វែងរកជំនួយ ។

# ៥. សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ៥.១- សេចក្ដីសន្និដ្ឋាន

យោងទៅតាមការសិក្សាស្រាវជ្រាវ ឯកសារស្រាវជ្រាវ និងរំលឹកទ្រឹស្ដី ធ្វើឱ្យយើងបានដឹងកាន់តែច្បាស់បន្ថែមទៀតទៅលើប្រធានបទស្ដីអំពី ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ក្នុងខេត្តសៀមរាបទាំងមូល ។ ចំពោះការអនុវត្តការការពារសិទ្ធិស្ត្រីរបស់សមាគមបានល្អ នោះប្រជាពលរដ្ឋ ជាពិសេសស្ត្រីរងគ្រោះក៏នឹងទទួលបាននូវយុត្តិធម៌នៃសិទ្ធិរបស់ខ្លួនផងដែរ ។ ហើយប្រសិនបើសមាគមអនុវត្តការការពារសិទ្ធិចំពោះស្ត្រី ឬប្រជាពលរដ្ឋមិនបានល្អនោះទេ នោះប្រជាពលរដ្ឋក៏នឹងពុំទទួលបាននូវសិទ្ធិ ឬយុត្តិធម៌របស់ខ្លួនបានដែរ ដែលវាក៏នឹងអាចមានជាផលអវិជ្ជមានដល់សមាគមដូចគ្នាដែរ ។

# ៥. សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ (ត)

## ៥.១- សេចក្តីសន្និដ្ឋាន (ត)

នៅក្នុងនោះផងដែរ ក្រុមរបស់យើងខ្ញុំក៏បានយល់ដឹងបន្ថែមទៀតអំពីចំណុចមួយចំនួនដូចជា ៖

- ប្រភពនៃការកើតមានឡើងនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី
- យន្តការនៃការអនុវត្តសិទ្ធិជូនប្រជាពលរដ្ឋរបស់សមាគមអាដហុក
- បញ្ហាប្រឈមរបស់ភ្នាក់ងារអនុវត្ត និងអង្គភាពផ្ទាល់
- ផលវិបាកដែលអង្គភាព និងមន្ត្រីអនុវត្តជួបប្រទះ
- ទិដ្ឋភាពនៃសង្គម ដែលក្រុមយើងខ្ញុំបានមើលឃើញថាបញ្ហារំលោភបំពាន គឺនៅតែមានការកើតមានឡើងនៅឡើយ ដោយគ្រាន់តែមានភាពប្រសើរឡើងច្រើនជាងមុន
- ប្រសិទ្ធភាពនៃការជួយអន្តរាគមន៍របស់អង្គការអាដហុក ។

# ៥. សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ (ត)

## ៥.២- ការផ្តល់អនុសាសន៍

- សមាគមគួរធ្វើយ៉ាងណាឱ្យមានការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចឱ្យបានកាន់តែល្អជាងនេះទៀត
- សមាគមអាជហុកគួររៀបចំឱ្យមានប្រព័ន្ធបញ្ចូលនូវទន្និន័យមួយ ដែលអាចផ្ទុកនូវសំណុំរឿងដែលទទួលបាន និងរក្សាជាឯកសារភស្តុតាងបានល្អផងដែរ ហើយម្យ៉ាងវិញទៀតវានឹងអាចជួយសម្រួលដល់និស្សិតក្រោយៗទៀត ប្រសិនបើចង់ចុះកម្មសិក្សានៅក្នុងសមាគមពេលក្រោយទៀត
- ដោយមើលឃើញថាសមាគមអាជហុកភាគច្រើន គឺចុះផ្សព្វផ្សាយទៅតាមសហគមផ្សេងៗ ហេតុដូច្នេះហើយ ក្រុមយើងខ្ញុំសូមឱ្យសមាគមអាជហុកគួរធ្វើការផ្សព្វផ្សាយនៅតាមសាលារៀនគ្រប់កម្រិតថ្នាក់ ដើម្បីឱ្យពួកគេបានយល់ដឹងកាន់តែច្បាស់អំពីវិធីការពារ និងផ្លូវសម្រាប់ដើរប្រសិនបើពួកគេត្រូវបានជួបរឿងនេះ សូមអរគុណ៕

UNIVERSITY OF SOUTH-EAST ASIA

# សូមអរគុណ!

# សំណួរ & ចម្លើយ

